កាន់តែទុកចិត្ត កាន់តែចំរើន

**ហត្ថាកសិករ លីមីតធីត**

**HATTHA KAKSEKAR LIMITED**

# របាយការណ៍ត្រីមាសទី២

## ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០

*ហត្ថាកសិករគឺជាបុត្រសម្ព័ន្ធរបស់ធនាគារក្រុងស្រី សមាជិក MUFG សម្ព័ន្ធក្រុមហ៊ុនហិរញ្ញវត្ថុសកល*

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | ត្រីមាសទី២ឆ្នាំ២០២០ | ២០១៩ | ២០១៨ |
|---|---|---|---|
| ទ្រព្យសកម្មសរុប (លានរៀល) | ៥ ៣៣៥ ២៥៩ | ៤ ៩៩៩ ៣២៣ | ៣ ៧១៦ ៩៦៦ |
| បំណុលសរុប (លានរៀល) | ៤ ៣៦៧ ៧៩១ | ៤ ១៩១ ០០៦ | ៣ ០៤៨ ៩៩៦ |
| មូលធនសរុប (លានរៀល) | ៩៦៧ ៤៦៨ | ៨០៨ ៣១៧ | ៦៦៧ ៩៧០ |
| **លទ្ធផលហិរញ្ញវត្ថុ** | **ត្រីមាសទី២ឆ្នាំ២០២០** | **ត្រីមាសទី២ឆ្នាំ ២០១៩** | **ត្រីមាសទី២ឆ្នាំ ២០១៨** |
| ចំណូលសរុប (លានរៀល) | ១៧០ ២០២ | ១៤២ ៦៩៤ | ១០៨ ៩៧៥ |
| ចំណេញ/(ខាត)មុនបង់ពន្ធ (លានរៀល) | -១៧ ៤៧២ | ៣២ ១១៨ | ២០ ១៦៤ |
| ចំណេញ/(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ (លានរៀល) | -១៤ ០១១ | ២៥ ៦៦២ | ១៦ ០៧៣ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ (លានរៀល) | -១៥ ២៨៥ | ២៩ ៤៥៧ | ១៩ ៩១៧ |
| **អនុបាតហិរញ្ញវត្ថុ** | **ត្រីមាសទី២ឆ្នាំ២០២០** | **២០១៩** | **២០១៨** |
| អនុបាតសាធនភាព (ភាគរយ) | ១៨,៦៤ | ១៩,៤ | ២០,០ |
| អនុបាតបំណុលធៀបនឹងមូលធន (ភាគរយ) | ៤៥១ | ៥១៨ | ៤៥៦ |
| អនុបាតសន្ទនីយភាព (ភាគរយ) | ២៣៥,៨ | ១១៣,៩ | ១៧៧,០ |
| អនុបាតឥណទានមិនដំណើរការ[1] (ភាគរយ) | ០,៦១ | ០,៣០ | ០,៦៧ |
| អនុបាតបញ្ញើឥណទាន (ភាគរយ) | ៥៣,៩ | ៥៧,០ | ៦៣,៤ |
| | **ត្រីមាសទី២ឆ្នាំ២០២០** | **ត្រីមាសទី២ឆ្នាំ២០១៩** | **ត្រីមាសទី២ឆ្នាំ ២០១៨** |
| អនុបាតចំណេញភាពធៀបនឹងទ្រព្យសកម្ម (ភាគរយ) | (០,២៦) | ០,៦១ | ០,៤៦ |
| អនុបាតចំណេញភាពធៀបនឹងមូលធន (ភាគរយ) | (១,៤៥) | ៣,៤៦ | ៣,៣៦ |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ភាគរយ) | ៧៥ | ១៥៧ | ១៤៩ |

[1] និយមន័យរបស់ធនាគារជាតិនៃកម្ពុជា

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប






# សមាសភាពក្រុមប្រឹក្សាភិបាល



លោក Dan HARSONO
ប្រធានក្រុមប្រឹក្សាភិបាល



លោកឧកញ៉ា ហួត អៀងតុង
អភិបាល



កញ្ញា Duangdao WONGPANITKRIT
អភិបាល



អ្នកស្រី Voranuch DEJAKAISAYA
អភិបាល



លោក Chandrashekar S.K.
អភិបាល



លោក Wanchairabin JITWATTANATAM
អភិបាល



លោក ឡុញ ហៃ
អភិបាលឯករាជ្យ



លោក ឌី ដាវុឌ្ឍ
អភិបាលឯករាជ្យ



លោក ប៉ាក សេរីវឌ្ឍនា
អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

**ជំងឺកូវីដ១៩** បានបង្កើតវិបត្តិសេដ្ឋកិច្ចដ៏លំបាកបំផុតមួយនៅក្នុងជីវភាពប្រចាំជីវិតរបស់យើងទាំងអស់គ្នា ដែលបានជះឥទ្ធិពលលើវិស័យសេដ្ឋកិច្ចពិភពលោកទាំងមូល ហើយយើងមិនអាចព្យាករណ៍ថាពេលណានឹងបញ្ចប់។ វាជាពេលវេលាដែលយើងត្រូវចាត់វិធានការយ៉ាងរហ័ស និងក្លាហានដើម្បីធ្វើឱ្យហត្ថាកសិករ លីមីតធីត មានជំហររឹងមាំក្នុងការគាំទ្រអតិថិជន និយោជិត និងអ្នកពាក់ព័ន្ធទាំងអស់។

សម្រាប់ប្រទេសកម្ពុជា ធនាគារពិភពលោក បានព្យាករណ៍ថា កំណើនផលិតផលក្នុងស្រុកសរុប(GDP) នឹងធ្លាក់ចុះក្នុងអត្រា ១,០ % តាមការឆ្លុះបញ្ចាំងពីការរងគ្រោះនៃសេដ្ឋកិច្ច ដែលជាលទ្ធផលពីការធ្លាក់ចុះលើវិស័យមួយចំនួនដូចជាៈការនាំចេញ ទេសចរណ៍ និងការវិនិយោគ។ ទោះបីជាអ្នកជំងឺកូវីដ១៩ សរុបនៅកម្ពុជាកើនដល់ ១៤១ នាក់ និងមានតែ ១១ករណី មិនទាន់ជាសះស្បើយនៅឡើយ នាចុងខែមិថុនានេះ ដែលបានបង្ហាញថា កម្ពុជាមានករណីកូវីដ១៩ តិចជាងបណ្តាប្រទេសភាគច្រើន ដោយបង្កផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនៅទូទាំងប្រទេស រួមទាំងអតិថិជនហត្ថាកសិករ លីមីតធីតផងដែរ។ ដូច្នេះ យើងបានប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីគ្រប់គ្រងស្ថានការណ៍នេះ និងធ្វើឱ្យប្រាកដថា រាល់អ្នកពាក់ព័ន្ធរបស់ហត្ថាកសិករ លីមីតធីត ទាំងអស់ទទួលបានការយកចិត្តទុកដាក់យ៉ាងល្អ។

អតិថិជនរបស់ហត្ថាកសិករ លីមីតធីតយើង ត្រូវបានជួយដោះស្រាយដោយយកចិត្តទុកដាក់បំផុត ក្នុងខែមេសា ឆ្នាំ២០២០ ហត្ថាកសិករ លីមីតធីត បានអនុវត្តកម្មវិធីការរៀបចំឥណទានសារឡើងវិញ ដើម្បីជួយដល់អតិថិជនដែលបានទទួលរងផលប៉ះពាល់ពី ជំងឺកូវីដ១៩ និងវិបត្តិសេដ្ឋកិច្ច។ កម្មវិធីការរៀបចំឥណទានសារឡើងវិញនេះ អនុញ្ញាតឱ្យអតិថិជនកាត់បន្ថយបន្ទុកបំណុលរបស់ពួកគាត់ក្នុងរយៈពេលរហូតដល់ ១២ ខែ អាស្រ័យទៅលើស្ថានភាពជាក់ស្តែង។ នៅចុងខែមិថុនា ឆ្នាំ២០២០ ហត្ថាកសិករ លីមីតធីត បានគាំទ្រជួយដល់អតិថិជនចំនួន ១១ ៣០៥ នាក់ តាមកម្មវិធីកាត់បន្ថយបំណុលជួយសម្រាលបន្ទុក ឱ្យស្របតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ហើយនឹងបន្តធ្វើរហូតនៅក្នុងឆ្នាំនេះ។ ចំពោះគុណភាពឥណទានអំឡុងពេល៣០ថ្ងៃ គឺមានហានិភ័យរហូតដល់ ២,៥៦% នៅចុងខែមិថុនា ឆ្នាំ២០២០នេះ ដែលបានឆ្លុះបញ្ចាំងឱ្យឃើញពីការលំបាកនៃការសងត្រលប់របស់អតិថិជន។ តែទោះយ៉ាងណាក៏ដោយ ផ្អែកលើការអនុវត្តសមរម្យ និងទាន់ពេលវេលានៃកម្មវិធីកាត់បន្ថយបំណុលជួយសម្រាលបន្ទុករបស់យើង គឺអាចគ្រប់គ្រងគុណភាពផលប័ត្រឥណទាននៅក្នុងកម្រិតដ៏ល្អបំផុត។

នៅខាងក្នុង ហត្ថាកសិករ លីមីតធីត បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ស្ថានភាពមិនល្អនេះ តាមរយៈសកម្មភាពដ៏ជាក់លាក់ទាំងប្រតិបត្តិការអាជីវកម្ម និងសកម្មភាពហិរញ្ញវត្ថុ ដែលត្រូវបានអនុវត្តយ៉ាងទាន់ពេលវេលា។ វិធានការណ៍សម្រាប់និយោជិត ត្រូវបានធ្វើឡើងយ៉ាងសកម្មទាក់ទងនឹងការការពារជំងឺកូវីដ១៩ ដូចជាការផ្សព្វផ្សាយ ការនៅឆ្ងាយពីសង្គមជួបជុំ ការត្រួតពិនិត្យសីតុណ្ហភាព និង អនាម័យដៃនៅកន្លែងធ្វើការ។ ផែនការបន្តអាជីវកម្ម (BCP) ត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ប្រសិនបើជំងឺកូវីដ១៩ មានការរីករាលដាលកាន់តែខ្លាំង នោះការធ្វើការងារនៅក្នុងការិយាល័យ គឺត្រូវបានកាត់បន្ថយឱ្យនៅតិចបំផុត។ មូលនិធិបន្តអាជីវកម្ម (Contingent Fund) ត្រូវបានរៀបចំយ៉ាងល្អសម្រាប់សាច់ប្រាក់ងាយស្រួល ប្រសិនបើមានការចាំបាច់ក្នុងការជួយឧបត្ថម្ភគាំទ្របន្ទាន់ ហត្ថាកសិករ លីមីតធីត មានធនាគារ Ayudhya(Krungsri) ដែលជាក្រុមហ៊ុនមេរបស់ខ្លួន។

ក្នុងដំណាច់ខែមិថុនាឆ្នាំ ២០២០ សំពៀតប្រាក់បញ្ញើសន្សំរបស់យើងបានកើនឡើង ៤% ដែលធ្វើឲ្យសមតុល្យកើនឡើងដល់ ៥៨១ លានដុល្លារអាមេរិក រីឯផលប័ត្រឥណទានរបស់យើងបានធ្លាក់ចុះពីចំនួន ១ ១០៤ លានដុល្លារអាមេរិក ក្នុងត្រីមាសទី ១ មកនៅត្រឹមចំនួន ១ ០៧៨ លានដុល្លារអាមេរិក ដោយសារការបញ្ចេញឥណទានមានការធ្លាក់ចុះ ក្នុងអំឡុងពេលមិនប្រាកដប្រជានៃខែមេសា និងឧសភា ហើយការអនុម័តប្រកាន់យក IFRS របស់ប្រទេសកម្ពុជា(CIFRS) ដែលជាបទដ្ឋានគណនេយ្យហិរញ្ញវត្ថុថ្មី។ លទ្ធផលហិរញ្ញវត្ថុនៅក្នុងត្រីមាសនេះ បានបង្ហាញថាមានការកើនឡើងយ៉ាងខ្លាំងពីការចំណាយលើសំវិធានធនចំពោះឥណទានមិនដំណើរការ ដើម្បីធានាភាពរឹងមាំក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ទោះជាយ៉ាងណាដ៏ដោយ ស្ថានភាពជាទូទៅ មានការវិវត្តប្រសើរឡើងច្រើននៅក្នុងខែមិថុនានេះ ដោយសារសកម្មភាពអាជីវកម្ម និងជីវភាពប្រចាំថ្ងៃ បានចាប់ផ្តើមដំណើរការឡើងវិញភាគច្រើន។ ការផ្តល់ប្រាក់កម្ចី និងការដាក់ប្រាក់បញ្ញើសន្សំរបស់យើង បានកើនឡើងយ៉ាងខ្លាំងក្នុងខែមិថុនានេះ ហើយនឹងនៅតែបន្តសម្រាប់ត្រីមាសបន្ទាប់ទៀត។

ជាធម្មតាមុនបញ្ចប់សេចក្តី ខ្ញុំសូមឆ្លៀតយកឱកាសនេះថ្លែងអំណរគុណដល់ និយ័តករ អតិថិជន និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ដែលបានគាំទ្រ និងជឿជាក់លើអាជីវកម្មរបស់យើង។ ទោះបីជាស្ថិតនៅក្នុងស្ថានភាពជំងឺកូវីដ១៩ក៏ដោយ យើងនឹងនៅតែបន្តពង្រឹង និងលើកកម្ពស់លើគ្រប់ផ្នែកសំខាន់ៗរបស់ហត្ថាកសិករ លីមីតធីត និងខិតខំប្រឹងប្រែងក្នុងការថែរក្សាអតិថិជន ក៏ដូចជាពង្រឹងគុណភាពផលប័ត្របន្តទៅទៀត។

កាលបរិច្ឆេទ៖ ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០២០

ហត្ថលេខា និង ត្រា

លោក Dan HARSONO

ប្រធានក្រុមប្រឹក្សាភិបាល

# សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក

ឆ្លើយតបទៅនឹងការរីករាលដាលជំងឺ COVID-19 លើសកលលោក ជាពិសេសនៅក្នុងប្រទេសកម្ពុជា នៅក្នុងអំឡុងពេល ខែមីនា រហូតដល់ ខែមិថុនា ឆ្នាំ២០២០ កន្លងទៅនេះហត្ថាកសិករ លីមីតធីត នៅតែបន្តប្រកាន់ភ្ជាប់ការប្រុងប្រយ័ត្នខ្ពស់ និងបានចូលរួមកំណារពារការរីករាលដាលនៃ ជំងឺ COVID-19 ដូចខាងក្រោម៖

១-ណែនាំបុគ្គលិកឲ្យលាងសំអាតដៃ សំអាតការិយាល័យជាប្រចាំ រក្សាគម្លាតសង្គមទៅតាមការណែនាំរបស់ក្រសួងសុខាភិបាល ។

២-បានដាក់ចេញនូវវិធានការចត្តាលីស័ក្តរយៈពេល ១៤ថ្ងៃ បន្ទាប់ពីសាមីបុគ្គលិក ឬសមាជិកក្រុមគ្រួសារត្រឡប់ពីក្រៅប្រទេសវិញ។

៣-ផ្តល់ជូនទឹកលាងដៃសម្លាប់មេរោគឥតគិតថ្លៃដល់បុគ្គលិក និងអតិថិជនគ្រប់ពេលវេលា។

៤- ធ្វើការត្រួតពិនិត្យសីតុណ្ហភាពបុគ្គលិក និងអតិថិជនទាំងអស់ ជាប្រចាំមុនពេលចូលការិយាល័យហត្ថាកសិករ លីមីតធីត។

៥- ផ្លាស់ប្តូរការបណ្តុះបណ្តាល និងប្រជុំដោយការជួបជុំផ្ទាល់ មកតាមអនឡាញវិញ។

៦- ធ្វើការផ្សព្វផ្សាយ ពីរបៀបការពារ ការចម្លងជំងឺ កូវីដ១៩ ដល់អតិថិជន និងបុគ្គលិក តាមរយៈបណ្តាញផ្សព្វផ្សាយនានារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត។

បើទោះបីមានផលប៉ះពាល់ជាអវិជ្ជមានពី ជំងឺ COVID-19 ផ្តល់ការអនុគ្រោះជូនអតិថិជន ក្នុងការរៀបចំឥណទានសាឡើងវិញ តាមការណែនាំរបស់ធនាគារជាតិនៃកម្ពុជា ដែលមានទឹកប្រាក់សរុបចំនួន $៨៨ លានដុល្លារអាមេរិក ជូនអតិថិជនចំនួន ១១ ៣០៥នាក់ ក៏ដោយ ហត្ថាកសិករ លីមីតធីត នៅតែឈរជើងយ៉ាងរឹងមាំនៅលើទីផ្សារហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជា។

យើងប្តេជ្ញាថានឹងផ្តល់នូវសេវាកម្មដ៏ល្អជាមួយ ផលិតផលថ្មី និងការគាំទ្រខ្ពស់បំផុតទៅតាមការប្រាថ្នាចង់បានពីអតិថិជន ហត្ថាកសិករ លីមីតធីត តែទោះជាយ៉ាងណាក៏ដោយក្នុងខណៈពេលនេះសូមអតិថិជនទាំងអស់បន្តថែរក្សាអនាម័យសុខភាពឲ្យបានល្អ និងអនុវត្តវិធីបង្កាជំងឺកូវីដ១៩ តាមការណែនាំរបស់ក្រសួងសុខាភិបាល។

គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ហត្ថាកសិករ លីមីតធីត ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុធំជាងគេទី២ នៅប្រទេសកម្ពុជាសម្រាប់ទ្រព្យសកម្ម ប្រាក់កម្ចី និងប្រាក់បញ្ញើសន្សំ។ ម្ចាស់ភាគហ៊ុនរបស់ហត្ថាកសិករ លីមីតធីតជាធនាគារ Ayudhya ដែលជាធនាគារធំលំដាប់ទី៥ ក្នុងប្រទេសថៃ និងជាសមាជិករបស់ MUFG ដែលជាសម្ព័ន្ធធនាគារធំជាងគេក្នុងប្រទេសជប៉ុន និងជាសម្ព័ន្ធហិរញ្ញវត្ថុធំមួយ ក្នុងពិភពលោក។ ហត្ថាកសិករ លីមីតធីត បានត្រៀមខ្លួនរួចជាស្រេច ទាំងធនធានមនុស្ស ទាំងដើមទុន និងបច្ចេកវិទ្យាព័ត៌មាន ក្នុងការក្លាយខ្លួនទៅជាធនាគារពាណិជ្ជ ដើម្បីបម្រើសេវាកម្ម និង ផលិតផលហិរញ្ញវត្ថុប្រកបដោយភាពស្មោះត្រង់ សាមញ្ញ និងមានវិជ្ជាជីវៈ ជាមួយនឹងទស្សនវិស័យឌីជីថលកាន់តែទំនើបជូនដល់អតិថិជន។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ ដែលបានប្តេជ្ញាចិត្តធ្វើឱ្យសម្រេចសមិទ្ធផលទៅតាមផែនការអាជីវកម្មឆ្នាំ២០២០ ទោះបីមានផលប៉ះពាល់ពីជំងឺកូវីដ-១៩ក៏ដោយ។ ខ្ញុំសូមកោតសរសើរ និងដឹងគុណចំពោះទំនុកចិត្ត និងការគាំទ្រពីសំណាក់អតិថិជន ដៃគូអាជីវកម្ម និងសាធារណជន ហើយខ្ញុំសង្ឃឹមនិងជឿជាក់ថាយើង នឹងផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុស្តង់ដាខ្ពស់បំផុតក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។

កាលបរិច្ឆេទ៖ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០២០
ហត្ថលេខា



លោកឧកញ៉ា ហួត អៀងតុង
ប្រធានអគ្គនាយក

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ....... i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ....... ii

សមាសភាពក្រុមប្រឹក្សាភិបាល ....... iiii

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ....... iv

សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក ....... v

ផ្នែកទី ១ ៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីមូលបត្រ ....... ១

ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ....... ១

ខ- លក្ខណៈនៃធុរកិច្ច ....... ១

គ. ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ....... ២

ផ្នែកទី ២ ៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ....... ២

ក.លទ្ធផលប្រតិបត្តិការធុរកិច្ច ....... ២

ខ-រចនាសម្ព័ន្ធចំណូល ....... ៣

ផ្នែកទី ៣ ៖ របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ ....... ៤

ផ្នែកទី ៤ ៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ....... ៥

ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ....... ៥

ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ....... ៥

គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ....... ៥

ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ....... ៥

ង-ផលប៉ះពាល់នៃអតិផរណា ....... ៦

ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ....... ៦

# ផ្នែកទី ១ ៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីមូលបត្រ

ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | ហត្ថាកសិករ លីមីតធីត |
| ឈ្មោះជាអក្សរឡាតាំង | Hattha Kaksekar Limited |
| អក្សរកូដ | HKL |
| អាសយដ្ឋាន | អគារលេខ ៦០៦ ផ្លូវ២៧១ ភូមិសន្សំកុសល ៣ សង្កាត់បឹងទំពន់ ទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ | ០២៣ ៩៩៤ ៣០៤ |
| គេហទំព័រ | www.hkl.com.kh |
| អ៊ីម៉ែល | info@hkl.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៥៣៥៥ (ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០១) |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ម.ហ ០២-១២/០៦/១១/០១ ចេញដោយ: ធនាគារជាតិនៃកម្ពុជា កាលបរិច្ឆេទ: ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ ១៦៥/១៨គ.ម.ក. កាលបរិច្ឆេទ: ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ |
| តំណាងHKLដោយ | លោក ហួត អៀងតុង |

ខ- លក្ខណៈនៃធុរកិច្ច

ហត្ថាកសិករ លីមីតធីត គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើសន្សំធំមួយ ទទួលបានអាជ្ញាប័ណ្ណ ពីធនាគារជាតិនៃកម្ពុជា និងបានធ្វើប្រតិបត្តិការជាង ២៦ឆ្នាំ មកហើយ។ ហត្ថាកសិករ លីមីតធីត បាននឹងកំពុងផ្តល់សេវាកម្មហិរញ្ញវត្ថុយ៉ាងសម្បូរបែបដល់អតិថិជនដូចជា៖ សេវាឥណទាន សេវាប្រាក់បញ្ញើសន្សំ សេវាផ្ទេរប្រាក់ក្នុងស្រុក សេវាអេធីអឹម សេវាធនាគារចល័ត សេវាបើកប្រាក់បៀវត្ស និងជាអ្នកណែនាំលក់សេវាធានារ៉ាប់រងផងដែរ តាមរយៈសាខាចំនួន ១៧៧ និងម៉ាស៊ីនអេធីអឹមចំនួន ១៣៧ទីតាំងនៅទូទាំងប្រទេស។ គិតត្រឹមខែមិថុនា ឆ្នាំ ២០២០ សមតុល្យប្រាក់បញ្ញើសន្សំ របស់ហត្ថាកសិករ លីមីតធីត មានចំនួនជាង ៥៨០ លានដុល្លារអាមេរិក ជាមួយនឹងចំនួនអតិថិជន ប្រាក់បញ្ញើសន្សំជាង ២៦១ ៨៨៣នាក់ និងផលប័ត្រឥណទានសរុបមាន ចំនួនប្រមាណ ១ ០៧៨ លានដុល្លារអាមេរិក ដែលបម្រើអតិថិជន ចំនួន ១៧១ ៩៩០នាក់។ បច្ចុប្បន្ន ហត្ថាកសិករ លីមីតធីត គឺជាបុត្រសម្ព័ន្ធរបស់ធនាគារ Krungsri ដែលជាធនាគារពាណិជ្ជធំជាងគេលំដាប់ទី ៥ នៅព្រះរាជាណាចក្រថៃ និងជាសមាជិករបស់សម្ព័ន្ធហិរញ្ញវត្ថុអន្តរជាតិ Mitsubishi UFJ Financial Group (MUFG) ដែលជាសម្ព័ន្ធធនាគារធំជាងគេបំផុតនៅប្រទេសជប៉ុន ព្រមទាំងជាសម្ព័ន្ធសេវាហិរញ្ញវត្ថុដ៏ធំមួយក្នុងចំណោម សម្ព័ន្ធហិរញ្ញវត្ថុ ធំជាងគេលើសកលលោក។

គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

បើទោះបីជាកម្ពុជា ក៏ដូចជាពិភពលោកទាំងមូលនៅតែបន្តរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីជម្ងឺកូវីដ ១៩ យ៉ាងនេះក្តី ហត្ថាកសិករលីមីតធីត នៅតែបន្តប្រតិបត្តិការរបស់ខ្លួនយ៉ាងរឹងមាំ និងប្រកបដោយទំនុកចិត្តពីអតិថិជន សាធារណជន និងគ្រប់ភាគីពាក់ព័ន្ធរបស់ខ្លួន។ ជាលទ្ធផល ហត្ថាកសិករបានផ្តល់អត្រាការប្រាក់យ៉ាងពិសេសត្រឹមតែ ៧% ក្នុងមួយឆ្នាំ ដើម្បីទ្រទ្រង់ សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាដែលជាផ្នែកមួយនៃការចូលរួមក្នុងគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម (SME Co-Financing Scheme) ក្រោមគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាល ក្នុងគោលបំណងផ្តល់ឥណទាន ជាមួយការប្រាក់ទាបដើម្បីជំរុញការអភិវឌ្ឍរបស់សហគ្រាសធុនតូច និងមធ្យមនៅក្នុងប្រទេសកម្ពុជា។ បន្ថែមពីលើនេះទៀត ហត្ថាកសិករលីមីតធីតដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈានមុខគេនៅក្នុងប្រទេសកម្ពុជា បានទទួលចំណាត់ថ្នាក់កម្រិត "BBB+" រយៈពេល២ឆ្នាំជាប់ៗគ្នាពីស្ថាប័ន TRIS Rating ដែលជាសមិទ្ធផលដ៏ត្រចះត្រចង់បន្ថែមមួយទៀតដែលបង្ហាញឲ្យកាន់តែច្បាស់ថា ហត្ថាកសិករលីមីតធីត គឺជាស្ថាប័នហិរញ្ញវត្ថុកំពុងតែមានប្រតិបត្តិការអាជីវកម្មប្រកបដោយស្ថិរភាព រឹងមាំ រីកចម្រើននៅលើទីផ្សារនាពេលបច្ចុប្បន្ន និងនាពេលអនាគតផងដែរ។

## ផ្នែកទី ២ ៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

ក- លទ្ធផលប្រតិបត្តិការធុរកិច្ច

| លទ្ធផលសម្រេចបានសំខាន់ៗ នាខែមីនា ឆ្នាំ២០២០ | ផែនការ | លទ្ធផលសម្រេចបាន |
|---|---|---|
| ផ្នែកសេវាឥណទាន | | |
| ចំនួនគណនីសេវាឥណទាន | ១៧១ ២៥១ | ១៧១ ៩៩០ |
| ឥណទាននៅក្នុងដៃអតិថិជន (ពាន់ដុល្លារអាមេរិក) | ១ ០៧៩ ៨៧៣ | ១ ០៧៧ ៧៣៧ |
| ផ្នែកសេវាប្រាក់បញ្ញើសន្សំ | | |
| ចំនួនគណនីសេវាប្រាក់បញ្ញើសន្សំ | ២៦១ ៩៦៣ | ២៦១ ៨៨៣ |
| សមតុលប្រាក់បញ្ញើសន្សំ (ពាន់ដុល្លារអាមេរិក) | ៥៨០ ០៦៦ | ៥៨០ ៩៥៥ |
| ផ្នែកសេវាកម្មផ្សេងៗទៀត | | |
| ចំនួនអ្នកប្រើប្រាស់កាតអេធីអឹម | ៥២ ០១២ | ៥១ ៤០៦ |
| ចំនួនអ្នកប្រើប្រាស់សេវាធនាគារចល័ត | ៨ ៧៦០ | ៨ ៧៧៧ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងខ្នាតតូច (ដុល្លារអាមេរិក) | ១២៥ ៤៩៥ | ១៣៥ ៧៤៦ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងអាយុជីវិតឥណទាន (ដុល្លារអាមេរិក) | ១ ៨៣៥ ២៤៧ | ២ ១៤៦ ៥៣៧ |

| ផ្នែកប្រតិបត្តិការសំខាន់ផ្សេងៗទៀត | | |
|---|---|---|
| ចំនួនការិយាល័យ | ១៧៧ | ១៧៧ |
| ចំនួនអេធីអឹម | ១៣៧ | ១៣៧ |
| ចំនួនបុគ្គលិក | ៥ ២០៩ | ៤ ៧៣៥ |

## ខ- រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី២ ឆ្នាំ ២០២០ | | ត្រីមាសទី២ ឆ្នាំ ២០១៩ | | ត្រីមាសទី២ ឆ្នាំ ២០១៨ | |
|---|---|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ |
| ១ | ចំណូលការប្រាក់ | ១៦៧ ០៤៣ | ៩៨,១ | ១៣៨ ០៦៣ | ៩៦,៨ | ១០៨ ៣០៧ | ៩៩,៤ |
| ២ | ចំណូលផ្សេងៗ | ៣ ១៥៩ | ១,៩ | ៤ ៦៣១ | ៣,២ | ៦៦៨ | ០,៦ |
| ចំណូលសរុប | | ១៧០ ២០២ | | ១៤២ ៦៩៤ | | ១០៨ ៩៧៥ | |

## ផ្នែកទី ៣៖ របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមពិនិត្យមើលរបាយការណ៍លម្អិតនៅក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ។

## ផ្នែកទី ៤ ៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ គឺជាការពិភាក្សាលើលទ្ធផលនៃប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ ពីគណៈគ្រប់គ្រងរបស់ ហត្ថាកសិករ លីមីតធីត ដោយផ្អែកទៅលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹម ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០២០ ហើយដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ។

របាយការណ៍ហិរញ្ញវត្ថុទាំងនេះរបស់ហត្ថាកសិករ លីមីតធីត ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់-ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

គណៈគ្រប់គ្រងធ្វើការពិភាក្សា និងវិភាគលើសមាសធាតុសំខាន់នៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗដែលបាន ជះឥទ្ធិពលទៅលើប្រាក់ចំណេញរបស់ហត្ថាកសិករ លីមីតធីតតែប៉ុណ្ណោះ ។

### ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

**ការវិភាគចំណូល**

ហត្ថាកសិករ លីមីតធីតមានចំណូល ២ប្រភេទធំៗគឺ ចំណូលពីការប្រាក់ និងចំណូលផ្សេងៗ

| | |
|---|---|
| **ចំណូលពីការប្រាក់រួមមាន៖** ចំណូលការប្រាក់សុទ្ធដែលទទួលបានពីការផ្តល់ឥណទានដល់ អតិថិជន និងពីការដាក់ប្រាក់បញ្ញើនៅតាមបណ្តា ធនាគារនានា។ ហើយចំណូលទាំងនេះត្រូវទទួលស្គាល់ជាប្រចាំខែ។ | **ចំណូលផ្សេងៗរួមមាន៖** កម្រៃណែនាំសេវាធានារ៉ាប់រង កម្រៃផ្ទេរ-ប្រាក់ ចំណូលកម្រៃផ្សេងៗ ចំណូលបានមកពីការប្រមូលឥណទានលុបចោល ចំណេញពីការប្តូរប្រាក់ ។ល។ |

ចំណូលការប្រាក់ ជាចំណូលដ៏ធំនិងសំខាន់សម្រាប់ ហត្ថាកសិករ លីមីតធីតដែលមានរហូតដល់ ៩៨,១% នៃចំណូលសរុប។

### ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ នេះ គណៈគ្រប់គ្រង់យល់ថា ហត្ថាកសិករ លីមីតធីត ការរីករាលដាលនៃ កូវីដ១៩ បានចាប់ផ្តើមមានផលប៉ះពាល់ជាអវិជ្ជមានដល់អាជីវកម្មជាពិសេសគឺ គុណភាពឥណទាន។

### គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០នេះ គណៈគ្រប់គ្រងយល់ថា ហត្ថាកសិករ លីមីតធីត បានចាប់ផ្តើមមានផលប៉ះពាល់ជាអវិជ្ជមានលើការលក់ និងចំណូលខុសពីធម្មតា។

### ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ហត្ថាកសិករ លីមីតធីត បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយប័ណ្ណគោលគឺ ប្រាក់ដុល្លារអាមេរិក។ ប្រតិបត្តិការជា រូបិយវត្ថុប្រាក់រៀល និងរូបិយប័ណ្ណប្រាក់ថៃបាត ត្រូវបានប្តូរទៅជា រូបិយប័ណ្ណគោលតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និង ខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ ការប្តូរទ្រព្យសកម្មនិងបំណុល រូបិយប័ណ្ណបរទេស ត្រូវបានកត់ត្រា នៅក្នុងរបាយការណ៍លទ្ធផលលម្អិត។

ង- ផលប៉ះពាល់នៃអតិផរណា

ហត្ថាកសិករ លីមីតធីតមិនបានកែប្រែអត្រាការប្រាក់ដោយផ្អែកតាមការប្រែប្រួលនៃអតិផរណាទេ ពោលគឺផ្អែកទៅលើស្ថានភាព ប្រកួតប្រជែងជាក់ស្តែងនៅក្នុងទីផ្សារ ហើយនៅតែរក្សាបាននូវចេរភាពហិរញ្ញវត្ថុយ៉ាងល្អប្រសើរ។

ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានៅតែបន្តអនុវត្តវិធានការសំខាន់ៗជាច្រើនដើម្បីធានាឲ្យបាននូវកំណើន និងស្ថិរភាពសេដ្ឋកិច្ច។ បន្ថែមលើវិធានការរូបិយវត្ថុមួយចំនួនដែលត្រូវបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជាកាលពីត្រីមាសទី១ ក្នុងឆ្នាំ២០២០ នៅក្នុងត្រីមាសទី២នេះ មានការដាក់ចេញនូវវិធានការរូបិយវត្ថុមួយចំនួនបន្ថែមទៀតដូចខាងក្រោម៖

- **គោលនយោបាយរូបិយវត្ថុ ទី១៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា បានផ្តួចផ្តើម និងបង្កើត “**គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាស់ធុនតូច និងមធ្យម**” ដែលមានទំហំទឹកប្រាក់ ១០០ លានដុល្លារសហរដ្ឋអាមេរិក ក្នុងគោលបំណងផ្តល់ឥណទានមានការប្រាក់ទាបដើម្បីជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមដែលបានចុះបញ្ជីផ្លូវការ នៅក្នុងប្រទេសកម្ពុជា។ ស្ថិតនៅក្រោមគម្រោងនេះ វិស័យអាទិភាពមួយចំនួនត្រូវបានផ្តល់រួមមាន៖ ផលិត និងកែច្នៃម្ហូបអាហារ, កម្មន្តសាលដែលផលិតទំនិញប្រើប្រាស់ក្នុងស្រុក កែច្នៃកាកសំណល់ និងផលិតទំនិញសម្រាប់វិស័យទេសចរណ៍, កម្មន្តសាលដែលផលិតនូវផលិតផលសម្រេច ឬផ្នែក ឬគ្រឿងបង្គុំ ដើម្បីផ្គត់ផ្គង់ឲ្យកម្មន្តសាលដទៃទៀត, ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រួមទាំងការផ្គត់ផ្គង់សេវាគ្រប់គ្រងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលមានលក្ខណៈនវានុវត្តន៍, និងសហគ្រាសដែលស្ថិតនៅក្នុងតំបន់ប្រមូលផ្តុំសហគ្រាសធុនតូច និងមធ្យម និងសហគ្រាសដែលអភិវឌ្ឍតំបន់នេះ។
- **គោលនយោបាយរូបិយវត្ថុ ទី២៖** ធនាគារជាតិនៃកម្ពុជា បានចេញគោលនយោបាយមួយផ្សេងទៀតឆ្លើយតបនឹងសំណើរបស់សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាដើម្បីធ្វើឱ្យស្ថាប័នហិរញ្ញវត្ថុមានសាច់ប្រាក់គ្រប់គ្រាន់ដើម្បីបន្តផ្តល់ជូនអតិថិជននៅក្នុងអំឡុងពេលការរីករាយដាលវីរុសកូវីដ ១៩។ គោលនយោបាយទាំងនោះរួមមាន៖

  - បន្ថយទ្រនាប់ដើមទុនខនសឺវេសិនចំនួន ១.២៥%។ ទន្ទឹមនេះ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនីមួយៗត្រូវមានផែនការច្បាស់ក្នុងការបំពេញបង្គ្រប់អនុបាតនេះឡើងវិញ នៅពេលស្ថានភាពសេដ្ឋកិច្ចវិលមកភាពប្រក្រតីវិញ និង

  - ទទួលស្គាល់ប្រាក់ចំណេញក្នុងត្រីមាសដែលបានធ្វើសវនកម្មរួច ដាក់បញ្ចូលក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធជាបណ្តោះអាសន្ន រហូតមានការជូនដំណឹងជាថ្មី ប៉ុន្តែគ្រឹះស្ថានមិនត្រូវបែងចែកភាគលាភដល់ភាគទុនិករបស់ខ្លួនទេ។

- **គោលនយោបាយរូបិយវត្ថុ ទី៣៖** ដើម្បីរួមចំណែករក្សាស្ថិរភាពថ្លៃ និងលើកកម្ពស់ប្រសិទ្ធភាពគោល នយោបាយរូបិយវត្ថុ ធនាគារជាតិនៃកម្ពុជា បានសម្រេចលើជំហរគោលនយោបាយរូបិយវត្ថុកាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០អំឡុងពេលកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុលើកទី៥១របស់ខ្លួន ដូចខាងក្រោម ៖

- ធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់តាមការចាំបាច់ ដើម្បីរក្សាស្ថិរភាពអត្រាប្តូរប្រាក់
- បន្តផ្គត់ផ្គង់សន្ទនីយភាពជាប្រាក់រៀលតាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)ក្នុងទំហំសមស្រប និង
- បន្តពង្រឹងការប្រើប្រាស់ប្រាក់រៀលឱ្យបានទូលំទូលាយ តាមវិធានការដែលមានស្រាប់ និងវិធានការតាមយន្តការទីផ្សារ។

## ហត្ថលេខារបស់អភិបាលហត្ថាកសិករ លីមីតធីត

កាលបរិច្ឆេទ៖ ១៤ ខែ សីហា ឆ្នាំ២០២០
បានអាន និងឯកភាព

លោក ឡូញ ហៃ
អភិបាលឯករាជ្យ

កាលបរិច្ឆេទ៖ ១៤ ខែ សីហា ឆ្នាំ២០២០
បានអាន និងឯកភាព

លោកបណ្ឌិត ឌី ដាវុឌ្ឍ
អភិបាលឯករាជ្យ

HKL

កាន់តែទុកចិត្ត កាន់តែចំរើន

ហត្ថាកសិករ លីមីតធីត

HATTHA KAKSEKAR LIMITED